# សហគមន៍ខ្មែរកម្ពុជាក្រោម

**THE KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTĖ DU KHMER KAMPUCHEA KROM**

លេខ: ……… ស.ខ.ក.ក.

# សេចក្តីអំពាវនាវ

សហគមន៍ខ្មែរកម្ពុជាក្រោម សូមលំឱនកាយក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមគោរពជម្រាបជូនបងប្អូនរួមឈាមខ្មែរទាំងអស់ ព្រះមេត្តានិងមេត្តាជ្រាបថា ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ជាខួបគម្រប់ ៦៥ឆ្នាំ (០៤-៦-១៩៤៩_០៤-៦-២០១៤) នៃប្រវត្តិសាស្ត្រដ៏ឈឺចាប់បំផុតរបស់ប្រជាជាតិខ្មែរ ដែលអាណានិគមបារាំងបានកាត់ទឹកដីខ្មែរកម្ពុជាក្រោម ប្រគល់ឲ្យអាណានិគមវៀតណាម។ ចាប់ពីពេលនោះមកបងប្អូនរួមឈាមខ្មែរនៅទីនោះ បានក្លាយជាជនជាតិភាគតិចនៅលើទឹកដីកំណើតរបស់ខ្លួន ហើយបានតស៊ូដ៏ស្វិតស្វាញ ដោយបានលះបង់សាច់ស្រស់ឈាមស្រស់នៃខេមរកុលបុត្រកុលធីតាក្នុងការប្រយុទ្ធ ដើម្បីភាពគង់វង្សពូជសាសន៍ សាសនា សិល្បៈ វប្បធម៌ អក្សរសាស្ត្រនិងទំនៀមទម្លាប់ខ្មែរដ៏ល្អផូរផង់ បានចាប់ធ្វើឡើងឥតឈប់ឈររហូតមកដល់សព្វថ្ងៃ។

ដើម្បីសំដែងនូវគារវកិច្ច និងកតញ្ញូតាធម៌ចំពោះវីរភាពដ៏អង់អាចក្លាហាននៃបុព្វបុរសខ្មែរស្នេហាជាតិ សហគមន៍ខ្មែរកម្ពុជាក្រោមនៅជុំវិញពិភពលោកបានរៀបចំពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន ១៩៤៩អង្គ និងប្រារព្ធជាទិវាកាន់ទុក្ខជាតិខ្មែរ ជារៀងរាល់ឆ្នាំ ដើម្បីឧទ្ទិសកុសលប្រគេន ថ្វាយ និងជូន ព្រះវិញ្ញាណក្ខន្ធ វិញ្ញាណក្ខន្ធ ព្រះវីរសមណៈ ព្រះវីរព្រះមហាក្សត្រ និងវីរបុរស វីរនារី វីរយុទ្ធជន វីរយុទ្ធនារីខ្មែរស្នេហាជាតិទាំងនោះ មិនដែលខកខានម្តងណាឡើយ។

សេចក្តីដូចបានប្រគេននិងជម្រាបជូនខាងលើ សហគមន៍ខ្មែរកម្ពុជាក្រោម សូមលំឱនកាយគោរពអំពាវនាវយ៉ាងទទូចដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនរួមឈាមទាំងអស់ ព្រះមេត្តានិងមេត្តាជួយឧបត្ថម្ភជាចង្ហាន់ព្រះសង្ឃ ទឹកបរិសុទ្ធ ឬជាថវិកាតាមសទ្ធាជ្រះថ្លាដល់គណៈកម្មការបុណ្យ ដើម្បីយើងខ្ញុំព្រះករុណា យើងខ្ញុំ មានលទ្ធភាពរៀបចំពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន ១៩៤៩អង្គនិងរំលឹកខួបទី ៦៥ឆ្នាំនៃថ្ងៃអាណានិគមបារាំងបានកាត់ទឹកដីខ្មែរកម្ពុជាក្រោម ប្រគល់ឲ្យអាណានិគមវៀតណាម បានសម្រេចជោគជ័យ។

សេចក្តីអំពាវនាវនេះ ចាត់ទុកជាសេចក្តីនិមន្តព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងអញ្ជើញបងប្អូនជនរួមជាតិ និងសប្បុរសជនទាំងអស់ ព្រះមេត្តានិងមេត្តា និមន្តនិងអញ្ជើញចូលរួមឲ្យបានច្រើនកុះករ ដើម្បីបង្ហាញសហគមន៍អន្តរជាតិឲ្យឃើញពីការឈឺចាប់ និងការសោកស្តាយអាល័យស្រណោះចំពោះការបាត់បង់ទឹកដីដ៏ជាទីស្រឡាញ់របស់យើងទាំងអស់គ្នា។

ការធ្វើវិភាគទាន ឬការអញ្ជើញចូលរួមរបស់បងប្អូនរួមជាតិក្នុងពិធីបុណ្យនេះ គឺជាការសំដែងនូវការគោរពនិងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះព្រះវិញ្ញាណក្ខន្ធ និងវិញ្ញាណក្ខន្ធ ព្រះវីរសមណៈ ព្រះវីរព្រះមហាក្សត្រ និងវីរបុរស-នារី យុទ្ធជន យុទ្ធនារីខ្មែរស្នេហាជាតិ ព្រមទាំងបានជាប្រយោជន៍ដ៏ធំធេងដល់ប្រជារាស្ត្រ និងមាតុភូមិខ្មែរកម្ពុជាក្រោមយ៉ាងពិតប្រាកដ។

កម្មវិធីបុណ្យនឹងប្រព្រឹត្តទៅក្រោមព្រះអធិបតីភាពព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃ**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ  នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ ចាប់ពីម៉ោង ៧:៣០នាទីព្រឹក រហូតដល់ម៉ោង ១២ថ្ងៃត្រង់ ។ ទីកន្លែង សួនច្បារមុខវត្តបទុមវតី (អតីតរោងអាយ៉ៃ) រាជធានីភ្នំពេញ។

គណៈកម្មការបុណ្យសូមថ្លែងអំណរព្រះគុណ និងអំណរគុណទុកជាមុន ចំពោះស្មារតីស្នេហាជាតិ និងសទ្ធាជ្រះថ្លារបស់បងប្អូនរួមជាតិ និងសូមឲ្យបានប្រកបដោយពុទ្ធពរទាំង ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕ សូមអរព្រះគុណនិងអរគុណ!

*រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែឧសភា ព.ស.២៥៥៧ គ.ស.២០១៤*

**នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម**

**ថាច់ សេដ្ឋា**
**អតីតសមាជិកព្រឹទ្ធសភា**

*សម្រាប់ព្រះករុណា ព្រះថេរានុត្ថេរៈ បងប្អូនជនរួមជាតិ និងសប្បុរសជន គង់និងរស់នៅសហរដ្ឋអាមេរិក ព្រមទាំងនៅ បណ្តាប្រទេសនានា សូមផ្ញើសែកបូរបិយវត្ថុទៅលោក ថាច់ រ៉ា តាមអាសយដ្ឋាននៅខាងក្រោម៖*

For U.S. residents and other countries, please kindly make payable personal check, traveler's check or money order and send it to Mr. Ra Thach:

**RA THACH**
P.O. BOX 37502
PHILADELPHIA, PA 19148
U.S.A.

--------------------------------------------------

*សម្រាប់ព្រះករុណា ព្រះថេរានុត្ថេរៈ បងប្អូនជនរួមជាតិ និងសប្បុរសជន គង់និងរស់នៅព្រះរាជាណាចក្រកម្ពុជា និងនៅ លើទឹកដីកម្ពុជាក្រោម សូមនិមន្តនិងអញ្ជើញទាក់ទងទៅអាសយដ្ឋានខាងក្រោម៖*

For residents of Cambodia and Kampuchea Krom, please kindly contact us at an address below:

The Khmer Kampuchea Krom Community, KKC
House No. 72, Street 426A, Koak Khlieng village, Phnom Penh Thmei commune
Sen Sok district, Phnom Penh, Kingdom of Cambodia
Tel.: (855) 78 360 898 / 93 47 47 06; E-mail: thachsetha13@gmail.com

--------------------------------------------------

*សម្រាប់ព័ត៌មានទូទៅ សូមព្រះករុណា ព្រះថេរានុត្ថេរៈ បងប្អូនជនរួមជាតិ និងសប្បុរសជន និមន្តនិងអញ្ជើញ ទាក់ទងទៅតំណាងសហគមន៍តាមរយៈលេខទូរស័ព្ទនិងអាសយដ្ឋានអ៊ីមែលដូចមាននៅខាងក្រោម៖*

General Contact Info:

| | | |
|---|---|---|
| គិម សកល | Sakal Kim | 978.596.5126 |
| គិម វុធ្ធី | Vithi Kim | 864.494.1991 |
| សឺន ស៊ីណា | Sina Son | 267.242.3608 |
| គិម សារេត | Saret Kim | 978.328.4435 |
| វិញ ថុន | Thol Vinh | 909.357.3344, 909.576.2192 |

For inquiries, please email us at this address: KKCpressoffice@yahoo.com.

សូមអរព្រះគុណ និងសូមអរគុណ ។

---

ទីស្នាក់ការ: ផ្ទះលេខ ៧២ ផ្លូវលេខ ៤២៦A ភូមិគោកឃ្លាង សង្កាត់ភ្នំពេញថ្មី
ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា; ទូរស័ព្ទលេខ: (៨៥៥) ៧៨ ៨៩៨ ៨៨២ / ៩៣ ៤៧ ៤៧ ០៦
អាសយដ្ឋានអ៊ីមែល: thachsetha13@gmail.com, kkcpressoffice@yahoo.com
Website: khmerkromngo.org; Facebook: khmerkkcommunity